# វដ្តកបរិត្ត (វដ្តកជាតក)

## (បិដក និង អដ្ឋកថា)

### បិដកភាគ ៥៨ ទំព័រ ១៦



រៀបរៀងដោយ ភិក្ខុ សារត្ថធម្មោ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# វដ្ដកបរិត្ត

(បិដកលេខ ៥៨ ទំព័រ ១៦ និងលេខ ៧៧ ទំព័រ ២៩៧)

**អត្ថិ លោកេ សីលគុណោ សច្ចំ សោចេយ្យនុទ្ទយា** *គុណនៃសីល ពាក្យពិត សេចក្ដីស្អាតកាយ និងសេចក្ដីករុណា (ទាំងនេះ) សឹងមានក្នុងលោក*

**តេន សច្ចេន កាហាមិ សច្ចកិរិយមនុត្តរំ** *ដោយពាក្យសច្ចៈនេះ ខ្ញុំនឹងធ្វើនូវសច្ចកិរិយាដែលឥតមានអ្វីស្មើឡើយ*

**អាវជ្ជិត្វា ធម្មពលំ　　សរិត្វា បុព្វកេ ជិនេ**
**សច្ចពលមវស្សាយ　　សច្ចកិរិយមកាសហំ**

*ខ្ញុំពិចារណានូវកម្លាំងនៃធម៌ហើយ រឭកនូវព្រះសម្ពុទ្ធទ្រង់ឈ្នះមារទាំងឡាយក្នុងកាលមុន អាស្រ័យនូវកម្លាំងនៃសច្ចៈហើយ បានធ្វើនូវសច្ចកិរិយា*

**សន្តិបក្ខា អបត្តនា　　សន្តិ បាទាអវញ្ចនា**
**មាតាបិតា ច និក្ខន្តា　　ជាតវេទ បដិក្កម**

*ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនបាន ជើងទាំងឡាយរបស់ខ្ញុំមានតែដើរមិនបាន មាតានិងបិតារបស់ខ្ញុំ បានចេញទៅហើយ (ព្រោះភ័យនឹងសេចក្ដីស្លាប់*[១]*) ម្នាលភ្លើងចូរអ្នកចៀសចេញទៅ*

**សហ សច្ចេ កតេ មយ្ហំ　　មហាបជ្ជលិតោ សិខី**
**វជ្ជេសិ សោឡស ករីសានិ　　ឧទកំ បត្វា យថា សិខី**

*នាកាលសច្ចៈដែលខ្ញុំបានធ្វើហើយ អណ្ដាតភ្លើងដ៏រុងរឿងធំចៀសចេញទៅហើយអស់ចម្ងាយទី ១៦ ករីសៈ ព្រមជាមួយនឹងពាក្យសច្ចៈរបស់ខ្ញុំ ដូចជាអណ្ដាតភ្លើងធ្លាក់ចុះដល់ទឹក*

---

១- ត្រង់បាទនៃគាថា ថា "**មាតា បិតា ច និក្ខន្តា**" នេះ ក្នុងប្រជុំភាណវារៈចាស់ លោកប្រែដាក់ក្នុងវង់ក្រចកថា "មាតា និងបិតារបស់ខ្ញុំចេញទៅរកអាហារហើយ" តែក្នុងអដ្ឋកថា លោកពន្យល់ថា "**មាតា បិតា ច និក្ខន្តាតិ យេ មំ អញ្ញត្ថ នេយ្យុំ, តេបិ មរណភយេន មម មាតាបិតរោ និក្ខន្តា**" បទថា **មាតា បិតា ច និក្ខន្តា** សេចក្ដីថា សូម្បីមាតាបិតាដែលនឹងនាំខ្ញុំទៅកាន់ទីដទៃនោះ ក៏ហើរទៅហើយ ព្រោះភ័យអំពីសេចក្ដីស្លាប់ (គឺខ្លាចស្លាប់)។ ហេតុនេះ ទើបយើងសម្រេចប្រែជាថ្មីតាមន័យរបស់អដ្ឋកថាវិញ បើយកតាមពាក្យប្រែដើមនុ៎ះ ក្រែងមិនមែនជាពាក្យសច្ចៈ។

**សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ** *អ្វីមួយស្មើដោយសច្ចៈរបស់ខ្ញុំមិនមានឡើយ នេះជាសច្ចបារមីរបស់ខ្ញុំ ។*

(ត្រឹមនេះមានក្នុងប្រជុំភាណវារៈ សម្រាប់សូធ្យ)

វដ្ដកជាតក ទី៥ (សេចក្ដីក្នុងបិដក)

[៣៥] (កូនចាបពោធិសត្វ ពោលថា) ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេ និងបា (របស់យើង) ចេញបាត់ទៅហើយ នៃភ្លើងព្រៃ អ្នកចូរថយទៅចុះ។

ចប់ វដ្ដកជាតក ទី៥។

# អដ្ឋកថា វដ្ដកជាតកទី ៥

(ពោលដោយសង្ខៈ)

[៣៥] *សន្តិ បក្ខា អបតនា សន្តិ បាទា អវញ្ចនា*
*មាតា បិតា ច និក្ខន្តា ជាតវេទ បដិក្កមាតិ ។*

*(កូនចាបពោធិសត្វ ពោលថា) ស្លាបទាំងឡាយមាន តែហើរ មិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេទិនិងបា (របស់យើង) ចេញបាត់ទៅហើយ នែភ្លើងព្រៃ អ្នកចូរថយទៅចុះ ។*

*ព្រះសាស្ដា កាលស្ដេចត្រាច់ចារិកទៅក្នុងមគធជនបទទាំងឡាយ ទ្រង់ប្រារព្ធការរលត់ភ្លើងព្រៃ ទើបត្រាស់ព្រះធម្មទេសនានេះថា សន្តិ បក្ខា (ស្លាបរបស់យើងមាន) ។*

*សេចក្ដីពិស្ដារ សម័យមួយ ព្រះសាស្ដាកាលស្ដេចត្រាច់ចារិកទៅក្នុងមគធជនបទទាំងឡាយ ស្ដេចបានត្រាច់បិណ្ឌបាតក្នុងស្រុកពួកអ្នកដែនមគធៈមួយកន្លែង ស្ដេចត្រឡប់អំពីបិណ្ឌបាត ខាងក្រោយកត្ត មានពួកភិក្ខុសង្ឃហែហម ស្ដេចយាងទៅតាមផ្លូវ ។ សម័យនោះ ភ្លើងព្រៃ*

ជាច្រើនឆេះឡើង ។ ភិក្ខុជាច្រើនឃើញទាំងខាងមុខ និងខាងក្រោយ ។ ជុំផ្សែង និងអណ្តាតភ្លើងឆេះទូទៅ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជនមួយពួកខ្លាចចំពោះមរណភ័យ ពោលថា “ពួកយើងនឹងដុតភ្លើងកាត់ផ្លូវភ្លើង ភ្លើងដែលឆេះមកមិនឆេះកន្លែងទីដែលភ្លើងនោះឆេះហើយទេ” ទើបនាំថ្ម និងដែកភ្លើងចេញមកដុតភ្លើង ។ ភិក្ខុមួយពួកទៀតពោលថា “អ្នកដ៏មានអាយុ ពួកលោកធ្វើអ្វី ពួកលោកមិនឃើញព្រះសម្មាសម្ពុទ្ធដែលជាបុគ្គលប្រសើរក្នុងលោកព្រមទាំងទេវលោក ស្តេចយាងទៅព្រមជាមួយខ្លួននោះឯង ដូចជាបុគ្គលមិនឃើញព្រះចន្ទអណ្តែតនៅក្នុងផ្ទៃអាកាស មិនឃើញព្រះអាទិត្យប្រដាប់ដោយរស្មីទាំងពាន់កំពុងរះឡើងចាកលោកធាតុអំពីទិសខាងកើត ដូចបុគ្គលឈរនៅត្រង់មាត់ទន្លេមិនឃើញទន្លេ ឬដូចបុគ្គលឈរលើភ្នំសិនេរុមិនឃើញភ្នំសិនេរុដូច្នោះ ទើបនាំគ្នានិយាយថា “ពួកយើងនឹងដុតភ្លើងកាត់ផ្លូវភ្លើង” ឈ្មោះថា ពួកលោកមិនដឹងព្រះកម្លាំងរបស់ព្រះពុទ្ធឡើយ” មក ពួកយើងនឹងទៅកាន់សម្នាក់ព្រះសាស្តា” ភិក្ខុទាំងនោះកាលទៅខាងមុខ និងខាងក្រោយសូម្បីទាំងអស់ បានរួមគ្នាទៅ

កាន់សម្នាក់ព្រះទសពល ។ ព្រះសាស្តាមានភិក្ខុពួកធំជាបរិវារ ទ្រង់បាន ប្រថាប់ឈរនៅក្នុងប្រទេសមួយ ។ ភ្លើងព្រៃឆេះបញ្ចេញសំឡេងដូចជា ទឹកជំនន់ គ្រាមកដល់ទីដែលព្រះតថាគតប្រថាប់ឈរ នៅប្រមាណ ១៦ ករីសៈជុំវិញប្រទេសនោះក៏រលត់ទៅ ដូចគប់ភ្លើងដែលគេជ្រលក់ចុះក្នុង ទឹកដូច្នោះ ។ មិនអាចឆាបឆេះក្នុងទីប្រមាណ ៣២ ករីសៈ ដោយអណ្តាត ភ្លើងចូលទៅ ។ ភិក្ខុទាំងឡាយនាំគ្នាពោលគុណព្រះសាស្តាថា "គួរ អស្ចារ្យ ឈ្មោះថា ព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ភ្លើងនេះសូម្បីមិន មានចិត្ត ក៏មិនអាចឆាបឆេះត្រង់ទីដែលព្រះពុទ្ធប្រថាប់ឈរ រមែងរលត់ ទៅ ដូចគប់ភ្លើងស្មៅរលត់ដោយទឹកដូច្នោះ ឈ្មោះថា អានុភាពរបស់ ព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យ" ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុ ទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រការដែលភ្លើងនេះមក ដល់ភូមិប្រទេសនេះហើយរលត់ទៅ ដោយកម្លាំងរបស់តថាគតមិនមែន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក៏ប្រការនេះជាកម្លាំងនៃសច្ចៈដែលមាន ក្នុងកាលមុនរបស់តថាគត ព្រោះថា ក្នុងប្រទេសនេះ ភ្លើងនឹងមិនឆេះអស់

នៃកប្បនេះសូម្បីទាំងអស់ នេះឈ្មោះថា បាដិហារ្យដែលតាំងនៅអស់នៃកប្ប" ។ លំដាប់នោះ ព្រះអានន្ទក្រាលសង្ឃាដិ ៤ ជាន់ ដើម្បីត្រូវការជាទីប្រថាប់គង់របស់ព្រះសាស្តា ។ ព្រះសាស្តាប្រថាប់អង្គុយពត់ភ្នែន ។ ឯភិក្ខុសង្ឃក៏ថ្វាយបង្គំព្រះតថាគតហើយ ក៏អង្គុយហែហម ។ លំដាប់នោះ ព្រះសាស្តាដែលភិក្ខុទាំងឡាយទូលអង្វរថា "បពិត្រព្រះអង្គដ៏ចម្រើន រឿងនេះប្រាកដហើយដល់ខ្ញុំព្រះអង្គទាំងឡាយមុនហើយ ចំណែករឿងអតីតនៅកំបាំង សូមព្រះអង្គប្រោសធ្វើរឿងអតីតនោះ ឲ្យប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយផងចុះ" ទើបទ្រង់នាំរឿងអតីតមកដូចតទៅនេះ

ក្នុងអតីតកាល ក្នុងប្រទេសនោះឯងក្នុងដែនមគធៈ ព្រះពោធិសត្វបានបដិសន្ធិក្នុងកំណើតសត្វក្រួច កើតអំពីផ្ទៃមាតា ក្នុងវេលាទម្លាយសម្បកចេញមក បានជាកូនក្រួច មានខ្លួនប្រមាណប៉ុនដុំរទេះផ្តុកទំនិញខ្នាតធំ ។ លំដាប់នោះ មាតាបិតាឲ្យព្រះពោធិសត្វនោះដេកក្នុងសំបុកហើយនាំអាហារមកចិញ្ចឹមដោយចំពុះ ។ ព្រះពោធិសត្វនោះមិនមានកម្លាំងដែលទីងលាស្លាបហើរទៅក្នុងអាកាស ឬមិនមានកម្លាំងទីងលើក

ជើងដើរទៅខាងលើទីទួល ឯភ្លើងព្រៃរមែងឆេះប្រទេសនោះរាល់ៗ ឆ្នាំ ។ សម័យនោះ ភ្លើងព្រៃនោះក៏ឆេះប្រទេសនោះខ្ទេចខ្ទី ។ ពួកបក្សីនាំគ្នាចេញចាកសំបុករៀងៗ ខ្លួន ព្រោះខ្លាចដល់មរណភ័យ បញ្ចេញសំឡេងស្រែកយំរត់ចេញទៅ ។ ព្រះពោធិសត្វដេកក្នុងសំបុកនោះឯង អើតកក្រឡេកឃើញភ្លើងព្រៃកំពុងឆេះប្រដេញមក ទើបគិតថា “បើយើងគប្បីមានកម្លាំងលាស្លាបហើរចេញទៅក្នុងអាកាស យើងក៏ទឹងហើរទៅកាន់ទីដទៃ បើយើងមានកម្លាំងអាចទឹងលើកជើងដើរទៅខាងលើគោកបាន ក៏យើងទឹងឈានជើងទៅកាន់ទីដទៃ ចំណែកមាតាបិតារបស់យើង ក៏ខ្លាចចំពោះមរណភ័យ លះបង់យើងទុកឲ្យនៅតែម្នាក់ឯង កាលទឹងការពារខ្លួន ទើបបានគេចចេញទៅ ឥឡូវនេះ ទីពឹងដទៃរបស់យើងមិនមាន យើងមិនមានទីពំនាក់ មិនមានទីពឹង ថ្ងៃនេះ យើងទឹងធ្វើយ៉ាងណាហ្ន៎ ទើបគួរ” ។

លំដាប់នោះ ព្រះពោធិសត្វមានការគិតយ៉ាងនេះថា “ក្នុងលោកនេះ ឈ្មោះថា គុណនៃសីលរមែងមាន ឈ្មោះថា គុណនៃសច្ចៈក៏រមែង

មាន ក្នុងអតីតកាល ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ដែលទ្រង់បំពេញបារមី ប្រចាំប់អន្ទុយត្រង់មណ្ឌលពោធិព្រឹក្ស បានត្រាស់ដឹងហើយ ទ្រង់ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ទ្រង់ប្រកបដោយសច្ចៈ សេចក្តីអាណិតអាសូរ ករុណា និងខន្តិ ទ្រង់ប្រកបដោយមេត្តាករុណាដែលប្រព្រឹត្តទៅហើយក្នុងសព្វសត្វទាំងឡាយ រមែងមាន និងគុណនៃព្រះធម៌ទាំងឡាយដែលព្រះសព្វញ្ញុពុទ្ធទាំងឡាយនោះទ្រង់ត្រាស់ដឹងហើយ រមែងមាន មួយទៀត សភាវៈសច្ចៈនេះឯងរមែងមានទៅក្នុងយើងដោយពិត សភាវធម៌នេះឯងរមែងមានប្រាកដ ព្រោះដូច្នោះ យើងនឹងរឭកដល់ព្រះពុទ្ធជាអតីតៈទាំងឡាយ និងគុណទាំងឡាយដែលព្រះពុទ្ធជាអតីតៈទាំងនោះត្រាស់ដឹងហើយ កាន់យកសភាវធម៌ គឺសច្ចៈដែលមានទៅក្នុងយើង ធ្វើសច្ចកិរិយា ឲ្យភ្លើងថយត្រឡប់ទៅ យើងគួរធ្វើសេចក្តីផុតភ័យដល់ខ្លួន និងពួកបក្សីដ៏សេសក្នុងថ្ងៃនេះ" ។ ព្រោះហេតុនោះ លោកទើបពោលថា

គុណនៃសីលក៏មានហើយក្នុងលោក សភាវៈសច្ចៈ

សេចក្តីស្អាត និងសេចក្តីអាណិតអាសូរ មានហើយក្នុង
លោក ដោយការៈសច្ចៈនោះ ខ្ញុំនឹងធ្វើសច្ចកិរិយាដ៏ឧត្តម
ខ្ញុំពិចារណាកម្លាំងនៃធម៌ រឭកដល់ព្រះជិនស្រីទាំងឡាយ
ក្នុងកាលមុន អាស្រ័យកម្លាំងសច្ចៈ សូមធ្វើសច្ចកិរិយា ។

លំដាប់នោះ ព្រះពោធិសត្វរឭកដល់ព្រះគុណព្រះពុទ្ធទាំងឡាយ ដែលព្រះអង្គបរិនិព្វានទៅហើយក្នុងអតីត ហើយប្រារព្ធសភាវៈ គឺ សច្ចៈ ដែលមានក្នុងខ្លួន កាលនឹងធ្វើសច្ចកិរិយា ទើបពោលគាថានេះថា

សន្តិ បក្ខា អបតនា    សន្តិ បាទា អវញ្ចនា
មាតា បិតា ច និក្ខន្តា    ជាតវេទ បដិក្កមាតិ ។

ស្លាបរបស់យើងមាន តែក៏ហើរមិនបាន ជើងទាំងពីររបស់
យើងមាន តែក៏ដើរទៅមិនបាន មាតា និងបិតារបស់យើង
ចេញទៅរកអាហារ ភ្លើង អ្នកចូរថយត្រឡប់ទៅវិញចុះ ។

បណ្តាបទទាំងនោះ បទថា សន្តិ បក្ខា អបតនា (ស្លាបរបស់យើងមាន តែក៏ហើរទៅមិនបាន) សេចក្តីថា ឈ្មោះថា ស្លាបទាំងពីររបស់

យើងមាន គឺ កើតមានហើយតែមិនអាចហើរ គឺ ទៅផ្លូវអាកាសដោយស្លាបទាំងនោះបាន ហេតុនោះ ទើបឈ្មោះថា ហើរមិនបាន ។ បទថា សន្តិ បាទា អវញ្ចនា (ជើងទាំងពីរបស់យើងមាន តែក៏ដើរមិនបាន) សេចក្តីថា សូម្បីជើងទាំងពីររបស់យើងក៏មានហើយ តែមិនអាចដើរ គឺ ទៅដោយការឈានជើងទៅដោយជើងទាំងពីរនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ដើរទៅមិនបាន ។ បទថា មាតា បិតា ច និក្ខន្តា (មាតាបិតារបស់យើងចេញទៅរកអាហារ) សេចក្តីថា ម្យ៉ាងទៀត សូម្បីមាតាបិតាដែលទីងនាំយើងទៅទីដទៃនោះ ក៏ចេញទៅហើយ ព្រោះភ័យខ្លាចស្លាប់ ។ ព្រះពោធិសត្វហៅភ្លើងថា ជាតវេទ: ។ ពិតហើយ ភ្លើងនោះពេលកើតក៏ដឹង គឺ ប្រាកដ ព្រោះដូច្នោះ ទើបហៅថា ជាតវេទ: កើតក៏ដឹង ។ ដោយបទថា បដិក្កម (ចូរថយត្រឡប់ទៅ) នេះ ព្រះពោធិសត្វបង្គាប់ទៅភ្លើងថា ចូរថយទៅ គឺ ចូរត្រឡប់ទៅ ។ ដូច្នោះ ព្រះមហា-សត្វដេកនៅក្នុងសំបុកនោះឯង បានធ្វើសច្ចកិរិយាថា “ប្រសិនបើស្លាបទាំងពីររបស់យើងមាន ១ ភាវ: គឺ ការលាស្លាបទាំងពីរហើរទៅកាន់

អាកាសមិនបាន ១ ការដែលជើងទាំងពីរមាន ១ ភាវៈ គឺ ការលើកជើងទាំងពីរនោះដើរទៅមិនបាន ១ ការដែលមាតាបិតាលះបង់យើងទុកចោលក្នុងសំបុកនោះឯងហើយគេចចេញទៅ ១ ទាំងអស់ជាសេចក្ដីពិតនោះឯង ភ្លើង ដោយពាក្យសច្ចៈនេះ អ្នកចូរត្រឡប់ទៅអំពីទីនេះ” ។

ព្រមជាមួយសច្ចកិរិយារបស់ព្រះពោធិសត្វនោះ ភ្លើងក៏បានថយត្រឡប់ទៅក្នុងទីប្រមាណ ១៦ ករីសៈ ។ ក៏កាលទីងថយទៅ ក៏ឆេះទៅកាន់ទីដទៃក្នុងព្រៃ ទាំងរលត់ហើយក្នុងទីនោះឯង ដូចគប់ភ្លើងដែលបុគ្គលជ្រលក់ចុះក្នុងទឹកដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា

កាលយើងធ្វើសច្ចៈ អណ្ដាតភ្លើងធំសន្ធោសន្ធៅគេចចេញទៅ
១៦ ករីសៈ ព្រមដោយពាក្យសច្ចៈ ហាក់ដូចជាអណ្ដាតភ្លើង
ដែលធ្លាក់ចុះក្នុងទឹកក៏រលត់ទៅដូច្នោះ (វត្ថុអ្វីស្មើដោយសច្ចៈ
របស់យើងមិនមាន នេះជាសច្ចបារមីរបស់យើង) ។

ក៏ស្ថានទីនេះឯង កើតជាបាដិហារ្យ ឈ្មោះថា តាំងនៅអស់នៃកប្ប ព្រោះភ្លើងនឹងមិនឆេះ ក្នុងកប្បនេះសូម្បីទាំងអស់ ។ ព្រះពោធិសត្វ

កាលធ្វើសច្ចកិរិយាយ៉ាងនេះហើយ ក្នុងវេលាអស់ជីវិត ក៏បានទៅតាមយថាកម្ម ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការដែលភ្លើងមិនឆេះស្ថានទីនេះ ជាកម្លាំងរបស់តថាគតក្នុងកាលឥឡូវនេះក៏មិនមែន ក៏កម្លាំងនោះជារបស់ចាស់ ជាសច្ចពលៈរបស់តថាគតឯងក្នុងគ្រានៅជាកូនក្រួច" លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ។ ក្នុងវេលាចប់សច្ចៈ ភិក្ខុទាំងឡាយពួកខ្លះក៏បានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ពួកខ្លះបានសម្រេចព្រះអរហត្ត ។

ចំណែកព្រះសាស្តាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា "មាតាបិតាក្នុងគ្រានោះ បានមកជាមាតាបិតាក្នុងកាលឥឡូវនេះ ចំណែកស្តេចក្រួចក្នុងកាលនោះ បានមកជាតថាគតនេះឯង" ។

ចប់អដ្ឋកថា វដ្ដកជាតកទី ៥